មជ្ឈមណ្ឌលឯកសារកម្ពុជា

# របាយការណ៍

## ស្តីពីទីតាំងប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម

ដោយ ផេង ពង្សរ៉ាស៊ី

នៅរសៀលថ្ងៃអាទិត្យទី២៦ខែឧសភាឆ្នាំ ២០០២ នៅតាមដងវិថីនានា ទាំងនៅទីក្រុងភ្នំពេញ និង នៅកន្លែងឯទៀតមានដិតដាមទៅដោយតំណក់ទឹកភ្លៀង និងមានចរាចរណ៍កកស្ទះដោយកន្លែងៗ នៅតាមផ្លូវ ជាតិលេខ៦ ឯណោះវិញតាមរយៈភ្លើងចង្កៀងរថយន្ត ខ្ញុំបានសង្កេតឃើញមានសត្វល្អិតជាច្រើនបានចេញមកទាំងហ្វូងៗបង្ហួតខ្លួន និងសំដែងនូវភាពក្លាហាររបស់ខ្លួនក្នុងការប្រឡែងលេងជាមួយទឹកភ្លៀងដែលកំពុងធ្លាក់ ខ្លះកៗដែលស្ទើរតែមើលផ្លូវមិនឃើញផង។ សត្វកង្កែប ហ៊ឹង បានលោតប្រជែងគ្នាដេញចាប់សត្វល្អិតៗធ្វើ ជាចំណីដោយមិនខ្វាចសេចក្តីស្លាប់។ រឿងហេតុនេះបានធ្វើឲ្យខ្ញុំគិតទៅដល់ការខិតខំប្រែងធ្វើការទាំងឈឺទាំងជា ដើម្បីប្តូរមកវិញនូវរបបអាហារប្រចាំថ្ងៃតាមលទ្ធភាពនៃកម្លាំង របស់ខ្លួនម្នាក់ៗ។ សត្វ«មេភ្លៀង»បានហើរ ព្រោងព្រាតហាក់ចង់ប្រកួតប្រជែងនឹងទឹកភ្លៀងដែលកំពុងធ្លាក់យ៉ាងសន្ធាប់។ នៅតាមដងវិថីឆ្ពោះទៅកាន់ខេត្ត កំពង់ចាម រថយន្តរបស់ខ្ញុំបានក្លាយទៅជាដំណើរផ្សងព្រេងតែម្នាក់ឯងនៅលើកំណាត់ផ្លូវជាតិដ៏រលោងស្រិល ដែលមានចម្ងាយ១២៤គីឡូម៉ែត្រពីទីក្រុងភ្នំពេញ។ ទោះជាយ៉ាងនេះក៏ដោយក៏គ្មានអ្វីគួរឲ្យបារម្ភឡើយពីរឿងសន្តិសុខ។ នៅវេលាម៉ោងប្រមាណ៨យប់ ក្រុមស្រាវជ្រាវខ្ញុំបានធ្វើដំណើរទៅស្នាក់នៅសណ្ឋាគារមេគង្គ ដែលមានទីតាំងស្ថិតនៅតាមបណ្តោយដងទន្លេបិទក្បែរគល់ស្ពានដែលទើបនឹងសាងសង់ថ្មី។

ព្រលឹមថ្ងៃទី២៧ខែឧសភាឆ្នាំដដែល ដោយស្ថិតក្នុងគោលបំណងច្បាស់លាស់មួយដែលបានរៀបចំតាំង ពីប៉ុន្មានថ្ងៃមុន ខ្ញុំបានធ្វើដំណើរទៅកាន់ស្រុកដំបែរទាំងព្រលឹមដោយឆ្លងកាត់ស្ពានទន្លេបិទ និងស្រុកត្បូងឃ្មុំ។

## ស្រុកដំបែរ

ក្នុងចម្ងាយដីប្រមាណជាង៨០គីឡូម៉ែត្រពីទីរួមខេត្តកំពង់ចាម ខ្ញុំបានធ្វើដំណើរអស់រយៈពេលជិតបីម៉ោងទើបទៅដល់សាលាស្រុកដំបែ។ គ្មាននរណាម្នាក់សោះនៅក្នុងការិយាល័យនៃសាលាស្រុកដ៏កញ្ជាសមួយមានតែក្មេងៗឃ្វាលគោដែលនៅអង្គុយលេងនៅក្រោមដើមឈើនាបរិវេណសាលាស្រុក។

ព្រំប្រទល់នៃស្រុកដំបែគឺ ខាងកើតជាប់នឹងស្រុកមេមត់, ខាងលិចជាប់នឹងស្រុកក្រូចឆ្មារ និង ស្រុកត្បូងឃ្មុំ, ខាងជើងជាប់នឹងស្រុកឆ្លូង ខេត្តក្រចេះ និងខាងត្បូងជាប់នឹងស្រុកពញាក្រែក។ សណ្ឋានដីនៃស្រុកនេះ ជាដីខ្ពង់រាប និងវាលទំនាបហើយដែលជាដីមានជីជាតិ។ ប្រជាជនភាគច្រើនជាអ្នក

ប្រកបរបរធ្វើស្រែចម្ការ និង ដាំកៅស៊ូជាលក្ខណៈគ្រួសារ ។ មានប្រជាជនភាគតិចណាស់ជាអ្នករកស៊ីលក់ដូរនិងជំនួញ ។ លក្ខណៈភូមិសាស្ត្រ នៃស្រុកនេះមិនមានភាពស្មុគស្មាញប៉ុន្មានទេ ។ មានឃុំចំនួន៧ ជាចំណុះនៃស្រុកដំបែគឺឃុំនាងទើច, ទឹកជ្រៅ, ត្រពាំងព្រីង, សេដា, ដំបែ, គោកស្រុក និងចុងជាច ។ ឃុំទាំងអស់នេះ គឺជាគោលដៅនៃការស្រាវជ្រាវ របស់ខ្ញុំនិងក្រុមស្រាវជ្រាវ ។

១) ឃុំនាងទើច

កាលពីឆ្នាំ១៩៩៨

ឃុំនេះបានត្រូវចុះពិនិត្យនិងសិក្សាស្រាវជ្រាវរួចហើយទៅលើទីតាំងតែមួយគត់គឺ ខ្ទរចាស់ ។ ខ្ទរចាស់ គឺជាទីតាំងសម្លាប់និងមន្ទីរសន្តិសុខតំបន់ដែលធំជាងគេនៅក្នុងស្រុកដំបែ ។ ក្រុមដែនទីបាន ប្រើប្រាស់ម៉ាស៊ីនកំណត់កូអរ៍ដោណេភូមិសាស្ត្ររួចរាល់ហើយ ។ ក្រៅពីទីតាំង ខ្ទរចាស់ នេះទៅ ឃុំនេះពុំមានទីតាំងសម្លាប់ ឬមន្ទីរសន្តិសុខណាផ្សេងទៀតទេសម្រាប់ធ្វើការស្រាវជ្រាវទេ ។

២) ឃុំសេដា

មេឃុំឈ្មោះ សែម ណែម បាយរាយការណ៍ពីទីតាំងប្រល័យពូជសាសន៍នៅក្នុងឃុំរបស់គាត់ប្រាប់ថា មានមន្ទីរសន្តិសុខមួយកន្លែងដែលប្រើប្រាស់ជាមន្ទីរសន្តិសុខប្រចាំស្រុកដំបែគឺ មន្ទីរសន្តិសុខព្រៃបុស្សក្រោល ។ មន្ទីរនេះមានឈ្មោះ កាន ជាប្រធានក្តាប់រួមនៅក្នុងមន្ទីរតាំងពីកកើតដំបូងនៅឆ្នាំ១៩៧៦រហូតដល់មន្ទីរនេះ ត្រូវបញ្ចប់នៅចុងឆ្នាំ១៩៧៨ ។ អ្នកទោសទាំងអស់ ត្រូវបញ្ជូនមកកាន់មន្ទីរស្រុកនៅភូមិខ្លាយសិន ទើបត្រូវ បញ្ជូនបន្តទៅកាន់មន្ទីរសន្តិសុខព្រៃបុស្សក្រោល ហើយបន្ទាប់នឹងធ្វើការសម្លាប់តែម្តង ។ ណែម បានបន្តថា អ្នកទោសទាំងអស់សុទ្ធតែជាយុទ្ធនារីរបស់ខ្មែរក្រហមដែលរត់ចោលជួរ ពេលត្រូវបញ្ជូនទៅកាន់ទួលដែនវៀត ណាមដើម្បីធ្វើសង្គ្រាម ។ ណែម បានប្រាប់ថាឃើញមានរោងចំនួនពីរដែលមានស្នាមចោះជញ្ជាំងដើម្បីស៊ក ខ្នោះដាក់អ្នកទោស ។ តាមការប៉ាន់ស្មានរបស់ ណែម ថាមានអ្នកទោសប្រហែល២០នាក់ប៉ុណ្ណោះបានជាប់នៅ ក្នុងរោងទាំងពីរនោះ ហើយដែលក្រោយមកបានត្រូវយកទៅសម្លាប់ចោលទាំងអស់នៅក្នុងរណ្តៅមួយក្បែរ នោះ ។ នៅក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ណែម បានទៅមើលទីតាំងនោះ ក៏ប្រទះឃើញមាន ឆ្អឹង និងអណ្តូងមួយ ព្រមទាំងមានបំណែកខោអាវផង ។

ព្រៃបុស្សក្រោល ស្ថិតនៅក្នុងព្រៃជ្រៅមួយក្នុងឃុំសេដា ស្រុកដំបែ ខេត្តកំពង់ចាម ។ ណែម បាន និយាយទៀតថា កម្រមាននរណាម្នាក់ហ៊ានធ្វើដំណើរទៅកាន់ទីនោះណាស់ ព្រោះជាព្រៃជ្រៅ

ដែលមាន ចម្ងាយ៥គីឡូម៉ែត្រពីភូមិ ។ ចំពោះការធ្វើដំណើរទៅកាន់ទីនោះ គឺត្រូវធ្វើដំណើរដោយថ្មើរជើង ។

ការបោះបង់ចោលទីតាំងមួយកន្លែងនេះ គឺជាគំនិតរបស់ខ្ញុំផ្ទាល់ ព្រោះខ្ញុំគិតថាអាចធ្វើឲ្យមានរឿងហេតុ ផ្សេងៗកើតឡើងចំពោះក្រុមស្រាវជ្រាវខ្ញុំ ។ នៅពេលក្រោយ ប្រសិនបើមានលទ្ធភាពខ្ញុំនឹងចុះស្រាវជ្រាវ ទៅលើទីតាំងនេះម្តងទៀត ។

៣) ឃុំត្រពាំងព្រីង

ជាឃុំមួយដែលស្ថិតនៅប៉ែកខាងជើងនៃស្រុកដំបែ ។ ខ្ញុំមិនបានធ្វើដំណើរទៅកាន់ឃុំនេះទេព្រោះមាន ព័ត៌មានមកថាមានអំពើចោរកម្ម និងប្លន់កើតមានជាញឹកញាប់ចំពោះអ្នកធ្វើដំណើរ ។ ម្យ៉ាងទៀតផ្លូវទៅកាន់ឃុំនេះមានលក្ខណៈពិបាក ។ ខ្ញុំមិនដឹងថានៅឃុំនេះមានទីតាំងប្រល័យពូជសាសន៍ប៉ុន្មានឡើយ ព្រោះគ្មានអ្នកផ្តល់ ព័ត៌មាន ។

៤) ឃុំទឹកជ្រៅ

នៅវេលាម៉ោងប្រហែល១១ថ្ងៃត្រង់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០២ ក្រុមខ្ញុំបានទៅជួបជាមួយអភិ បាលរងស្រុកដំបែរនៅនឹងផ្ទះរបស់គាត់ និងហួសទៅជួបជាមួយមេឃុំទឹកជ្រៅ ដើម្បីសាកសួរពីទីតាំងប្រល័យ ពូជសាសន៍ ។ ជាលទ្ធផល ខ្ញុំបានទទួលពត៌មានថាមានទីតាំងប្រល័យពូជសាសន៍មួយស្ថិត នៅខាងជាយឃុំឯ ណោះ ។ ទីតាំងនោះមានឈ្មោះថា**ជាំត្រកួន** ។ ជាំត្រកួន គឺជាតំបន់ដាច់ស្រយ៉ាល មួយ ដែល មិនងាយនឹងធ្វើ ដំណើរទៅដល់ឡើយ ។ ដោយសារតែមានភ្លៀងធ្លាក់ជាប់ៗគ្នា ទើបក្រុមខ្ញុំមិនអាចធ្វើដំណើរទៅបានឡើយ និងម្យ៉ាងទៀតមានរបាយការណ៍ពីមន្ទីរឃុំមកថាមានអំពើចោរកម្ម និងប្លន់ផ្សេងៗដែលអាចនឹងកើតមានជា យថាហេតុផង ។ ទីតាំងនេះត្រូវការធ្វើដំណើរ ឆ្លងកាត់ តាមចម្ការកៅស៊ូជាច្រើនកន្លែងទើបទៅដល់ទីនោះ ។ ជាំត្រកួន គឺជាមន្ទីរឃុំឃាំង និងកន្លែងសម្លាប់របស់ខ្មែរក្រហម ។ ប្រជាជន១៧មេសាជាច្រើនគ្រួសារបានត្រូវជាប់នៅក្នុងមន្ទីរសន្តិសុខជាំត្រកួន ហើយដែលក្រោយមកបានត្រូវយកទៅសម្លាប់ទាំងអស់នៅក្នុង រណ្តៅ B-52 ដែលទម្លាក់ដោយទាហាននៃរបបលន់ណុល ។

៥) ឃុំចុងជាច

មានទីតាំងចំនួនពីរគឺ ត្រពាំងត្នោត និងបុស្សប្ញក្ដីរស្ថិតនៅក្នុងឃុំចុងជាច ។ ត្រពាំងត្នោត គឺជាឈ្មោះនៃមន្ទីរសន្តិសុខស្រុកទឹកជ្រៅ(ឈ្មោះស្រុកនៅក្នុងរបបខ្មែរក្រហមដែលបច្ចុប្បន្នជាស្រុកដំបែ) ។

*មន្ទីរសន្តិសុខ នេះស្ថិតនៅខាងជើងភូមិតារាមប្រហែល៣គីឡូម៉ែត្រ ។ បុស្សបន្ទី គឺជាទីតាំងសម្លាប់ ។ ជនរងគ្រោះដែលបាន បញ្ជូនមកពីគុកត្រពាំងត្នោត បានត្រូវយកមកដាក់បណ្តោះអាសន្ននៅភូមិតាមាយថ្មី ហើយបន្ទាប់មកត្រូវយក មកសម្លាប់ទាំងអស់នៅបុស្សបន្ទីនេះ ។*

*ទីតាំងទាំងពីខាងលើ ថ្វីត្បិតតែបានទទួលពត៌មានខ្លះៗ ប៉ុន្តែក្រុមស្រាវជ្រាវខ្ញុំមិនអាចចុះទៅដល់បាន ឡើយ ។ មូលហេតុនៃការមិនចុះទៅនេះ គឺបណ្តាលមកពីទីតាំងនេះស្ថិតនៅឆ្ងាយដាច់ស្រយាល ពីភូមិដែលមាន ប្រជាជនរស់នៅច្រើន និងគ្មានផ្លូវសម្រាប់ធ្វើដំណើរតាមកង់ ម៉ូតូ ឬរថយន្តឡើយ ។ គ្រាន់តែចំណាយពេល ទៅលើការធ្វើដំណើរទៅកាន់ទីតាំងនេះ គឺត្រូវចំណាយពេលអស់ជិតមួយថ្ងៃ ។ ខ្ញុំបានត្រឡប់មកកាន់ឃុំដំបែ វិញនៅរសៀលម៉ោងជិត៣ថ្ងៃដដែល ។*

*៦) ឃុំដំបែរ*

*ព្រៃមន្ទីរកុមារ (ទីតាំងសម្លាប់)*

*លេខកូតភូមិសាស្ត្រ ០៣០៤០៣*

*រយៈកំពស់* **(N) 12º 00'17:95"**

*រយៈទទឹង* **(E) 105º 52'58:22"**

*ខ្ញុំបានធ្វើដំណើរកាត់តាមសាលាស្រុកដំបែ ឆ្ពោះមកទិសខាងលិចប្រហែលជាង១០គីឡូម៉ែត្រ តាមផ្លូវ អភិវឌ្ឍន៍មួយខ្សែរបស់អង្គការ«*Trip*» រួចទើបបត់ទៅកាន់ទិសខាងជើងតាមផ្លូវលេខ៧៣ ប្រហែល៥គីឡូម៉ែត្រ ទៀតទើបទៅដល់ទីតាំងសម្លាប់មួយកន្លែងឈ្មោះថាមន្ទីរកុមារ ។ មន្ទីរកុមារគឺជាមន្ទីរដែលស្ថិតនៅក្នុងព្រៃជ្រៅ មួយកន្លែងក្នុងភូមិជ័យសម្បត្តិ ឃុំដំបែ ស្រុកដំបែ ។ មន្ទីរនេះបានត្រូវសាងសង់ឡើងដើម្បីធ្វើជាមន្ទីរអប់រំ កែប្រែក្មេងៗ ដែលចូលចិត្តលួចនេះលួចនោះកាលពីអំឡុងឆ្នាំ ១៩៧៥-៧៦ ។ លុះដល់ឆ្នាំ១៩៧៧រហូតមក ដល់ចុងឆ្នាំ១៩៧៨ មន្ទីរកុមារនេះបានក្លាយទៅជាកន្លែងឃុំឃាំងបណ្តោះអាសន្នមួយ សម្រាប់ស្តុបអ្នកទោស ដែលបម្រុងយកទៅសម្លាប់នៅក្នុងព្រៃមួយខាងក្រោយមន្ទីរនេះប្រហែល២០០ម៉ែត្រ ។ មុំ អៀច អាយុ ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិជ័យសម្បត្តិ ឃុំដំបែ ស្រុកដំបែ បានប្រាប់ថា អ្នកទោសទាំងអស់ត្រូវបណ្តើរយក មកចងនៅក្នុងមន្ទីរកុមារនេះ ហើយក្រោយមកត្រូវអូសតាមច្រកទ្វារក្រោយនៃមន្ទីរយកទៅកាន់កន្លែងសម្លាប់ ដោយគ្មាននរណាម្នាក់ដឹងឡើយ ។ ជនរងគ្រោះដែលត្រូវបាននាំយកទៅសម្លាប់នោះបានត្រូវស្គាល់យ៉ាងច្បាស់ថាជាទាហានដែលពិការផ្នែកសមត្ថភាព ។ ហ៊ិន គឿ អាយុ៥៤ឆ្នាំ ជាប្រធានឃុំដំបែ បាននិយាយថា ទាហាន ទាំងនេះបានត្រូវចាប់ខ្លួន និងយកមកផ្ញើតាមសហករណ៍នានាក្នុងឃុំដំបែទាំងមូល ។ គាត់រំឭកទៀតថា ទាហាន ទាំងនេះសុទ្ធតែជាមនុស្សអសមត្ថភាពខាងសឹកសង្គ្រាម ។ ដូច្នេះអ្នកទាំងនោះត្រូវតែ*

មករស់នៅក្នុងសហករណ៍ ជាមួយប្រជាជនដើម្បីធ្វើស្រែចម្ការ និងលើកផ្លូវ ។ នៅឆ្នាំ១៩៧៣ ទាហានពិការទាំងនោះត្រូវបានចាប់ខ្លួន ។ នៅឆ្នាំ១៩៧៦ ទាហានទាំងនោះត្រូវសម្លាប់ទាំងអស់តាមរូបភាពកុហកបោកប្រាស់ពីពួកខ្មែរក្រហមថាត្រូវទៅ បន្តការរៀនសូត្រ និងហ្វឹកហាត់បន្ថែមនូវបច្ចេក-ទេសខាងសង្គ្រាម ។ ការកុហកនេះត្រូវ មុំ អៀច រៀបរាប់ ថា បានធ្វើឡើយដោយខ្មែរក្រហមខាងនិរតី ។ រយៈពេលបីថ្ងៃនៃការសម្លាប់ ទីតាំងមន្ទីរកុមារបានត្រូវហាម ឃាត់ចំពោះការឆ្លងកាត់ផ្សេងៗ ។ សារ៉េត សព្វថ្ងៃរស់នៅភូមិជ័យសម្បត្តិ ឃុំដំបែ បានបញ្ជាក់ពីរឿងនេះថា គាត់ត្រូវហាមឃាត់ដោយក្មេងខ្មែរក្រហមដែលនិយាយរដឹនៗនៅក្បែរមន្ទីរកុមារនោះ ក្នុងខណៈពេលដែលគាត់ មានបំណងចូលទៅបេះបន្លែបង្ការយកមកធ្វើម្ហូបដើម្បីសហករណ៍ ។ ផុតពីរយៈពេលនៃការហាមឃាត់នេះទៅ មន្ទីរកុមារដែលពីមុនធ្លាប់តែមានមនុស្សទាំងគ្រួសារៗរស់នៅ ត្រូវប្រែក្លាយជាកន្លែងដែលស្ងាត់ជ្រងំគួរឲ្យខ្លាច ។ ឯការចេញចូលនានាត្រូវកាត់បន្ថយដោយគ្មានការបង្ខំ ។ ហៀង ហឿង អាយុ៤២ឆ្នាំ បាននិយាយថា គាត់បានបណ្តើរឆ្កែចូលទៅក្នុងព្រៃនោះនាឆ្នាំ១៩៧៦ ដើម្បីរកសត្វ ។ ពេលទៅដល់ទីតាំងនោះស្រាប់តែគាត់ បានប្រទះឃើញមានសាកសពស្លាប់ពេញអណ្តូងទឹកចំនួន២ និងរណ្តៅបេចំនួន១ ។ ហឿង មានអារម្មណ៍ភ័យ ខ្លាចនឹងសភាពការណ៍បែបនេះ ហើយគាត់ក៏បានត្រឡប់ទៅកាន់ផ្ទះរបស់គាត់វិញ ដោយបានពាំនាំទៅជាមួយ នូវដំណឹងពីការសម្លាប់មនុស្សនៅក្នុងអណ្តូង និងរណ្តៅបេទៅប្រាប់គេឯងគ្រប់គ្នាឲ្យដឹងពីរឿងនេះ ។ ក្រោយមក ហឿង បានរត់គេចខ្លួនពីការតាមចាប់របស់ខ្មែរក្រហម ។ កំហុសនៃការតាមចាប់នេះ ហឿង បានរាយការណ៍ ថា មកពីគាត់ដឹងពីការសម្លាប់មនុស្សនៅក្នុងព្រៃខាងក្រោយមន្ទីរកុមារ ។ ហឿង បានបន្តទៀតថា សាកសព ទាំងនោះសុទ្ធតែគាត់ធ្លាប់បានជួបកាលពីពេលខ្មែរក្រហមបណ្តើរមកបញ្ចូលក្នុងមន្ទីរកុមារ ។ ជនរងគ្រោះប្រ មាណ៦០០នាក់បានត្រូវដឹកជញ្ជូនមកពីស្រុកមេមត់មុនពេលសម្លាប់បន្តិច ។ ថ្វីត្បិតតែពេលនោះ ហឿង ទើបតែមានអាយុជាង១០ឆ្នាំ ប៉ុន្តែព្រឹត្តិការណ៍ទាំងអស់បានធ្វើឲ្យ ហឿង ព្រឺក្បាលនិងខ្លាចសេចក្តីស្លាប់ជាពន់ពេក ។ ជាសំណាងល្អ ហឿង បានរួចផុតពីសេចក្តីស្លាប់ ហើយបានរស់រានមានជីវិតរហូតដល់បច្ចុប្បន្ន ។ ហឿង បានជូនខ្ញុំនិងក្រុមស្រាវជ្រាវទៅពិនិត្យមើលទីតាំងដោយផ្ទាល់ ព្រមទាំងបានធ្វើបទសម្ភាសន៍យ៉ាងវែង មួយដល់ខ្ញុំ ។ ហឿង បាននិយាយថា ថ្វីត្បិតតែគាត់រស់នៅទីនេះ(ភូមិជ័យសម្បត្តិ) ប៉ុន្តែគាត់មិនដែលបានមក ដល់ទីតាំងសម្លាប់ទេ ព្រោះនាំឲ្យគាត់នឹកឃើញតែរឿងមិនសប្បាយចិត្ត ។ រណ្តៅបេនិងអណ្តូងទឹកចំនួនពីរទៀត នៅតែមានស្លាកស្នាមនៅឡើយ ជាមួយនឹងការដុះយ៉ាងប្រជ្រៀតគ្នានៃរុក្ខជាតិទាំងឡាយ ។

៧) ឃុំគោកស្រុក

វត្តថ្មី (ទីតាំងសម្លាប់)

លេខកូតភូមិសាស្ត្រ ០៣០៨០៨

រយៈកំពស់ **(N) 11º 59'40:33"**

រយៈទទឹង **(E) 105º 51'07:32"**

បន្ទាប់ពីការងារនៅឃុំដំបែបានត្រូវបញ្ចប់ទៅ ខ្ញុំបង្ហួសមកធ្វើការនៅក្នុងឃុំគោកស្រុកទៀត ។ ស្ថិតនៅ តាមបណ្តោយផ្លូវលេខ៧៣ ក្រុមខ្ញុំបានធ្វើដំណើរមកដល់វត្តមួយឈ្មោះថា វត្តថ្មី ដែលជាទីតាំងសម្លាប់កាលពី ជំនាន់ខ្មែរក្រហម ។ ប្រជាជនមូលដ្ឋានភាគច្រើនដែលបច្ចុប្បន្នរស់នៅក្នុងទឹកដីកំណើតរបស់ខ្លួន បានដឹងគ្រប់ៗ គ្នាថា នៅក្នុងបរិវេណវត្តថ្មីនេះមានការសម្លាប់មនុស្សដាក់នៅក្នុងរណ្តៅB-52មួយ និងមួយទៀតគឺអណ្តូងទឹក ។ រឿងហេតុនេះបានកើតឡើងនៅក្នុងចុងឆ្នាំ១៩៧៧ ហើយបន្តរហូតមកដល់ចុងឆ្នាំ១៩៧៨ ។ ភូមិភាគបូព៌ា ទាំងមូលបានត្រូវរង្គោះរង្គើរដោយសារតែសោភឹមបានក្បត់នឹងបដិវត្តន៍ ។ ប្រជាជនស្លូតត្រង់ជាច្រើនបានត្រូវ សម្លាប់ទាំងហ្វូងៗដោយគ្មានពិចារណាអ្វីឡើយ ។ ចំណែកកម្មាភិបាលខ្មែរក្រហមខាងបូព៌ាទាំងអស់បានត្រូវចាប់ ខ្លួន និងសម្លាប់ស្ទើរអស់ ។ កម្មាភិបាលខាងភូមិភាគនិរតីបានចូលខ្លួនមកគ្រប់គ្រងជំនួសគ្រប់តំណែងទាំងអស់នៅ ភូមិភាគបូព៌ា ដោយសមមិត្តក្មេងៗ ។ ការជម្លៀសប្រជាជនមូលដ្ឋានបានចាប់ផ្តើមធ្វើឡើង ដោយឲ្យធ្វើដំណើរទៅកាន់ខេត្តកំពង់ស្ពឺ និងកំពង់ធំ ។ ក្នុងការជម្លៀសនេះ អ្នកខ្លះបានត្រូវសម្លាប់ព្រោះតែភាពរឹងរូស និង តមាត់តករដល់កម្មាភិបាលក្មេងៗទាំងនោះ ។

នាង ខន ជាប្រធានភូមិឈើទាលជ្រុំបាននិយាយប្រាប់ថា នៅពេលដែលគាត់កំពុងត្រូវជម្លៀសចេញ ទៅលិច(គោលដៅប្រហែលជាខេត្តកំពង់ស្ពឺនិងកំពង់ធំ) ស្រាប់តែឃើញមានអ្នកខ្លះបានបណ្តើរបញ្ច្រាសទិសជា មួយគាត់ឆ្ពោះមកកាន់វត្តថ្មីនេះដើម្បីសម្លាប់ ។ ខន បានគេចខ្លួនជាមួយគ្រួសាររបស់គាត់ក្នុងពេលជម្លៀសបានបន្តិច ។ ខន ព្រមទាំងគ្រួសារបានវិលត្រឡប់ក្រោយមករកផ្ទះដែលគាត់បានស្នាក់នៅពីមុនមក ។ ខន បានជួបប្រទះហេតុការណ៍ដ៏ចម្លែកមួយ គឺមានការសម្លាប់មនុស្សនៅក្នុងបរិវេណវត្តថ្មីដែលស្ថិតនៅក្នុងភូមិឈើទាលជ្រុំ ឃុំគោកស្រុក ស្រុកដំបែ ។ ខន ធ្លាប់បានជាប់ទោសនៅក្នុងវត្តថ្មី ដោយសារមូលហេតុមិនព្រមជម្លៀសទៅ តាមអ្នកឯទៀត ព្រមទាំងបានទទួលទណ្ឌកម្មយ៉ាងច្រើនពីសន្តិសុខទៀតផង ។ ក្រោយមក ខន បានលួចរត់គេចខ្លួនទៅកាន់ស្រុកកំណើតឪពុករបស់គាត់នៅខេត្តព្រៃវែងជាមួយក្រុមគ្រួសាររបស់គាត់ ។

ការសម្លាប់មនុស្សនៅវត្តថ្មី បានត្រូវល្បីខ្ចរខ្ចាយពីមាត់មួយទៅមាត់មួយស្ទើរតែពេញឃុំគោក ស្រុក ទាំងមូល ដោយសារការឃើញច្បាស់នឹងភ្នែកនូវចំនួនសាកសពយ៉ាងច្រើននៅក្នុងអណ្តូងទឹក និង រណ្តៅបេ ។ ខន បានរៀបរាប់ថា នៅពេលដែលគាត់បានត្រឡប់មកពីស្រុកកំណើតរបស់ឪពុកគាត់ មកវិញ ក៏បានទៅកាន់វត្តថ្មីដែលពេលនោះគឺចំពេលដែលមានការជីករកមាសពីប្រជាជនក្នុងស្រុក ទៅ លើរណ្តៅបេនិងអណ្តូងនោះ ។ ខន បានឃើញមានឆ្អឹងយ៉ាងច្រើននៅលើមាត់រណ្តៅ ហើយដែលភាគ ច្រើនគឺជាឆ្អឹងក្មេងៗ ព្រោះមានលលាដ៏ ក្បាលសុទ្ធតែតូចៗ ។ ចំណែកអណ្តូងវិញ ក៏មានឆ្អឹងច្រើនដែរ ប៉ុន្តែ ខន បានប្រាប់ថាមានភាគច្រើនជាមនុស្ស ចាស់ ។

នៅក្នុងបរិវេណវត្តថ្មីនេះ មានរណ្តៅបេចំនួនមួយនៅប៉ែកខាងកើតព្រះវិហារជាប់នឹងផ្លូវជាតិ លេខ៧៣ និងអណ្តូងមួយទៀតស្ថិតនៅចម្ងាយប្រហែល១០០ម៉ែត្រពីរណ្តៅបេប៉ែកខាងលិច ។ ចំពោះ ការប៉ាន់ស្មានចំនួន សាកសពដែលបានស្លាប់នៅក្នុងអណ្តូង និងរណ្តៅខាងលើ ខន បានសន្និដ្ឋានតាម ដែលគាត់បានឃើញផ្ទាល់ភ្នែក នូវចំនួនឆ្អឹងលលាដ៏ក្បាលដែលបានបោះមកលើដីថា មានចំនួនប្រហែល ជាង៤០ក្បាល ។ ចំណែកឯនៅក្នុង ប៉ុន្មានទៀត គាត់មិនបានដឹងឡើយ ។

## ស្រុកចម្ការលើ

*១) អណ្តូងតាស៊ុន ឬអណ្តូងអាស្វើន*

*លេខកូតភូមិសាស្ត្រ ០៣០២១១*

*រយៈកំពស់* **(N) 12º 20'00:03"**

*រយៈទទឹង* **(E) 105º 11'32:58"**

ដីឡូមួយកន្លែង ដែលស្ថិតនៅប៉ែកខាងត្បូងឈៀងខាងលិចសាលាឃុំចម្ការអណ្តូងនាពេលបច្ចុប្បន្ននេះ បានលាក់បំពួននូវ ទីតាំងសម្លាប់មនុស្សធំៗចំនួនពីរកន្លែងគឺ អណ្តូងតាស៊ុនឬអណ្តូងអាស្វើន អស់រយៈពេលជាង២០ឆ្នាំ កន្លងមកហើយ ។ ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំចម្ការអណ្តូងទាំងមូល មានតែមួយផ្នែកនៃប្រជាពល រដ្ឋប៉ុណ្ណោះដែលបានដឹងពីការសម្លាប់មនុស្សនេះ ។ រឿងរ៉ាវនៃការសម្លាប់រង្គាលនៅក្នុងអណ្តូងតាស៊ុន បានត្រូវរ៉ាយរ៉ាប់ប្រាប់ដោយលោកមេឃុំចម្ការអណ្តូងដល់ក្រុមស្រាវជ្រាវខ្ញុំដូចតទៅៈ

នៅឆ្នាំ១៩៧៧ មានអ្នកទោសជាច្រើនពាន់នាក់ដែលភាគច្រើនជាប្រជាជន១៧មេសា, អ្នក ដែលជាប់និន្នាការនយោបាយពីសង្គមចាស់ និងប្រជាជនដែលបានជម្លៀសមកពីស្រុកបារាយណ៍ ខេត្ត កំពង់ធំ បានត្រូវ ដឹកដោយរថយន្តធំៗ ជាច្រើនគ្រឿងចូលទៅកាន់ទីតាំងសម្លាប់នៅក្នុងបរិវេណដីឡូ

របស់តាស៊ុន និងដីឡូផ្សេងដទៃទៀតដែលស្ថិតនៅប៉ែកខាងត្បូងផ្លូវធំដែលមានប្រជាជនរស់នៅច្រើន ។ គោលបំណងនៃការជម្លៀសនេះ គឺយកមកសម្លាប់ចោល ។ ការបោកប្រាស់ជាពាក្យសម្តីទាំងឡាយបានត្រូវធ្វើឡើងចំពោះប្រជាជនទាំងនោះ ។ គ្មាននរណាម្នាក់ដឹងថាជាការកុហកយកមកសម្លាប់ឡើយ ។ ទីបំផុតការសម្លាប់បានប្រព្រឹត្តិឡើងនៅស្ទើរតែជា រៀងរាល់ថ្ងៃ ។ ដោយឡែកនៅក្នុងអណ្តូងចំនួន២ នៃបរិវេណដីឡូរបស់តាស៊ុន មានជនរងគ្រោះមួយផ្នែកបាន ត្រូវសម្លាប់ទម្លាក់អណ្តូងដោយព្រនង់ ។ ជនរងគ្រោះដែលបានស្លាប់ទាំងនោះមានចំនួនប្រហែល១០០០នាក់ នៅក្នុងអណ្តូងទឹកធំៗចំនួន២ដែលមានជម្រៅប្រហែលជាង១០ម៉ែត្រ ។

ម៉ែន មួង អាយុ៤៨ឆ្នាំ ជាប្រធានឃុំចម្ការអណ្តូងបានបន្តថា វត្តចម្ការអណ្តូងគឺជាទីស្នាក់អាស្រ័យរបស់ឃាតករខ្មែរក្រហមក្នុងអំឡុងពេលសម្លាប់មនុស្ស ។ ទីវត្តនេះក៏ជាកន្លែងសួរចម្លើយ និងធ្វើ ទារុណកម្មមក លើអ្នកទោសដែរ ។ ក្នុងករណីនេះគឺកើតមានតែចំពោះប្រជាជនមូលដ្ឋានប៉ុណ្ណោះ ដែលបានប្រព្រឹត្តិខុសនឹងបទបញ្ជារបស់អង្គការ ។ មួង បានឃើញផ្ទាល់នឹងភ្នែកនូវឈាមប្រឡាក់ពេញខ្លួនពួកឃាតករនៅពេលដែលពួកគេ ត្រឡប់មកពីធ្វើការវិញ ។ ជាលទ្ធផលគ្មានអ្នកទោសណាម្នាក់បានរួចខ្លួនពីសេចក្តីស្លាប់ឡើយ ។ ការសម្លាប់មនុស្សយ៉ាងសាហាវឃោរឃៅនេះបានត្រូវ មួងធ្វើការសន្និដ្ឋានថា ជាការសម្លាប់តាមផែនការដែលបាន ប្រគល់ពីថ្នាក់លើ ។ មួង បានបន្តទៀតថា គាត់បានឮផ្ទាល់នឹងត្រចៀកនូវសម្តីរបស់កម្មាភិបាលម្នាក់(មិនស្គាល់ឈ្មោះ) និយាយថា ពួកគេ(ខ្មែរក្រហម) មានផែនការសម្លាប់មនុស្សឲ្យអស់ក្នុងអំឡុងឆ្នាំ១៩៧៨-៧៩ ព្រោះនឹងបានដឹកជញ្ជូនជនជាតិចិនមកដាក់ជំនួសវិញ ។ តាំងពីនោះមក មួងបានសង្កេតឃើញមានជនជាតិចិន ខ្លះៗបានមកធ្វើការនៅក្នុងស្រុកចម្ការលើដោយស្ថិតក្នុងភាពអាថ៌កំបាំងបំផុត ។

នៅឆ្នាំ១៩៧៨ ការសម្លាប់មនុស្សនៅស្រុកចម្ការលើ បានត្រូវផ្អាកសកម្មភាពយ៉ាងតក់ក្រហល់បំផុត ដោយសារតែមានសារាចរណ៍មួយពីគណៈ៨៧០មកថា លែងឲ្យមានការសម្លាប់មនុស្សតទៅទៀត ។ ផែង ពល់ បច្ចុប្បន្នជាកម្មករចាក់ជ័រកៅស៊ូនៅក្នុងភូមិលេខ១ ឃុំចម្ការអណ្តូងបាននិយាយថាគាត់ជាប្រជាជន ដែលមានស្រុកកំណើតនៅក្នុងខេត្តកំពង់ធំ ប៉ុន្តែដោយមានការជម្លៀសពីខ្មែរក្រហមតាំងពីជំនាន់ដែលគ្រប់គ្រង ដោយរបបកម្ពុជាប្រជាធិបតេយ្យមកកាន់ស្រុកចម្ការលើ ទើបរហូតមកដល់ពេលនេះ គាត់នៅតែបន្តរស់នៅទី នេះរហូតមក ។ ពល់ ជាកម្មការនីម្នាក់ដែលមានចិត្តអំណត់អត់ធ្មត់បំផុតនៅពេលធ្វើការ ។ ពល់ បានបង្ហើបប្រាប់ថា គាត់បានខំប្រឹងប្រែងធ្វើការគ្មានថ្ងៃឈប់ឡើយ ព្រោះចង់បាននូវរបបនៃការហូបចុកគ្រប់គ្រាន់ ។ ទោះជាយ៉ាងនេះក្តី គាត់ក៏ត្រូវមានឈ្មោះយកទៅសម្លាប់ចោលដែរ ។ ជាសំណាងរបស់គាត់ ពល់ បានរួចខ្លួនពីការសម្លាប់ដោយសារ

តែសារាចរណ៍របស់គណៈ៨៧០ បានធ្លាក់មកអនុវត្តន៍ទាន់ពេល ។ ចំណែកការដឹកជញ្ជូនមនុស្សពីកន្លែងផ្សេងៗ មកសម្លាប់ក៏ត្រូវផ្អាក និងក្រោយមកបន្តិចក៏បានបញ្ឈប់ជាបន្ទាន់ ។ គំរោងផែនការសម្លាប់មនុស្សដោយវិធីសាស្ត្រហៅមកប្រជុំដោយដាក់បង្កើគ្រាប់បែកឲ្យស្លាប់ទាំងអស់ ក៏ត្រូវខកខានទៅវិញ ការគ្រប់គ្រងបែបផ្តាច់ការ បានប្រែក្លាយទៅជាភាពធម្មតាតែក្នុងរយៈពេលខ្លីបំផុតសម្រាប់ប្រជាជនទូទៅ មុន នឹងថ្ងៃរំដោះ៧ ខែមករា ឆ្នាំ១៩៧៩ចូលមកដល់ ។

ចាប់តាំងពីឆ្នាំ១៩៧៩មក រណ្តៅទាំងឡាយបានត្រូវគាស់ឡើងក្នុងគោលបំណងតែមួយគឺរកមាស និង វត្ថុមានតម្លៃដទៃទៀត ។ ឆ្អឹងទាំងឡាយបានគរចោលនៅលើដីក្បែររណ្តៅដែលគាស់នោះ ។ ក្រោយមកក៏មាន ការប្រមែប្រមូលយកទៅថែរក្សាទុកនៅវត្តចម្ការអណ្តូងដែរ ប៉ុន្តែដោយការធ្វេសប្រហែស ឆ្អឹងទាំងនោះបាន ត្រូវបំផ្លាញអស់ដោយសត្វពាហនៈ និងពុកផុយ ។

២) សន្តិសុខចម្ការកៅស៊ូគីឡូលេខ២ (សន្តិសុខ និងទីតាំងសម្លាប់)

លេខកូតភូមិសាស្ត្រ ០៣០២១២

រយៈកំពស់ **(N) 12º 21'13:53"**

រយៈទទឹង **(E) 105º 12'59:99"**

មន្ទីរឃុំឃាំងមួយកន្លែងបានត្រូវសាងសង់ឡើងដើម្បីឃុំឃាំងអ្នកទោសដែលជាប្រភេទអ្នកលួចនេះលួចនោះខ្ជិលច្រអូសមិនធ្វើការ កម្មករចម្ការកៅស៊ូ និងទាហានដែលខុសឆ្គងនឹងវិន័យរបស់អង្គការជាដើម ។ សន្តិសុខនេះមិនមែនជាសន្តិសុខរបស់ស្រុក ឬតំបន់ទេ ប៉ុន្តែវាជាសន្តិសុខរបស់ឃុំចម្ការអណ្តូង ។ មន្ទីរសន្តិសុខនេះ មិនមានឃុំឃាំងប្រភេទប្រជាជន១៧មេសាទេ ប៉ុន្តែមានឃុំឃាំងច្រើនជាប្រភេទប្រជាជនដែលជាប់ពាក់ពន្ធ័នឹងនិន្នាការនយោបាយពីសង្គមចាស់ ។ ពលកម្មធ្ងន់ៗបានធ្លាក់មកលើអ្នកទោសទាំងនោះជាអ្នកអនុវត្តន៍ ។ របបអាហារត្រូវបានកំណត់តាមកម្លាំងពលកម្មដែលបានបញ្ចេញ ។ ផែង ពល់ ជាអតីតអ្នកទោសនៅក្នុងមន្ទីរសន្តិ សុខនេះ ហើយដែលបច្ចុប្បន្នរស់នៅភូមិលេខ១ ឃុំចម្ការអណ្តូង ស្រុកចម្ការលើ បានប្រាប់ពីការជាប់ទោស របស់គាត់ប្រាប់ថា មានការលំបាកខ្លាំងណាស់ចំពោះការធ្វើពលកម្មនៅក្នុងគុក ។ ពល់បានបន្តថា មានភាគតិចបំផុតដែលមានការអត់ទ្រាំហើយអាចរស់នៅរហូតដល់សព្វថ្ងៃនេះ ។ ការសម្លាប់មនុស្សបានប្រព្រឹត្តិទៅជា រៀងរាល់ថ្ងៃចាប់តាំងពីមន្ទីរនេះបានបង្កើតដំបូងនៅឆ្នាំ១៩៧៦-៧៧ ។ ពល់បានប្រាប់ថា ខ្លួនគាត់បានដឹង ថាមានការសម្លាប់មនុស្សច្រើនណាស់ នៅចម្ការកៅស៊ូគីឡូលេខ២នេះ ប៉ុន្តែគាត់មិនបានដឹងពីចំនួនពិតប្រាកដឡើយ ។ ប្រធានឃុំចម្ការអណ្តូង ម៉ែន មួង បានបន្ថែមថា គាត់បានឃើញរណ្តៅចំនួនពី៣០ទៅ៤០រណ្តៅ ។

រណ្តៅទាំងនោះបានត្រូវគាស់ឡើង បន្ទាប់ពីមានការផ្លាស់ប្តូររបបសង្គមពីកម្ពុជាប្រជាធិបតេយ្យមកជាសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ក្រោយពីការគាស់ មួង បានសង្កេតឃើញថាមានឆ្អឹង និងលលាដ៍ក្បាលយ៉ាងច្រើន នៅពាសពេញដីនៃចម្ការកៅស៊ូ ។ ចំនួនទាំងនោះបានត្រូវ មួង ធ្វើការសន្និដ្ឋានថាមានចំនួនប្រហែលពី៣០០ទៅ៤០០សាកសព ។ សាកសពទាំងនេះ បានត្រូវសម្លាប់ដោយកងសន្តិសុខដែលស្ថិតនៅក្រោមបញ្ជារបស់ សាត ជាមេសន្តិសុខនៅចម្ការកៅស៊ូគីឡូ៧ ។ សាត ជាមនុស្សដែលបានបញ្ជូនមកពីភូមិភាគនិរតីឲ្យមកកាន់កាប់នៅទីនេះ ។ ការសម្លាប់មនុស្សនៅចម្ការកៅស៊ូគីឡូលេខ៧នេះ មិនមែនស្ថិតនៅក្នុងផែនការសម្លាប់ទេ ប៉ុន្តែវាជាការសម្លាប់ដើម្បីព្រមាននូវទោសកំហុសដែលខ្លួនផ្ទាល់បានប្រព្រឹត្តិខុសនិងអ្វីដែលអង្គការចង់បាន ។ ម៉ែន មួង បានប្រាប់ថាមានគ្រួសារមួយនោះ (ភ្លេចឈ្មោះ) បានត្រូវយកទៅសម្លាប់ទាំងគ្រួសារដោយសារមូល ហេតុមានបងប្អូនធ្វើជាទាហានសម័យលន់ ណុល ។ នៅប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៨ មានសារាចរណ៍របស់គណៈ៨៧០ មួយបានចេញឲ្យអនុវត្តន៍នូវគ្រប់កន្លែងទាំងអស់ ដែលសារាចរណ៍នោះមានអត្ថន័យជាចំហរថា "ឲ្យផ្អាកការសម្លាប់មនុស្ស" ។ សារាចរណ៍នេះ បានចេញយឺតពេលបន្តិចចំពោះការសម្លាប់មនុស្សអស់ជាង៣០០នាក់ នៅមន្ទីរសន្តិសុខចម្ការកៅស៊ូគីឡូលេខ៧ ។ ផែង ពល ជាអ្នកទោសម្នាក់ដែលត្រូវយកទៅសម្លាប់ដូចគេឯងដែរ ប៉ុន្តែគាត់បានត្រូវដោះលែងវិញបន្ទាប់ពីសារាចរណ៍នេះបានចេញប្រកាសជាផ្លូវការមក ។ ពល់ បានអានសារាចរណ៍នេះដោយផ្ទាល់នឹងភ្នែក ហើយបានដឹងច្បាស់ថាពិតជាមានការលើកលែងចំពោះការ សម្លាប់មនុស្សពិតមែន និងព្រមទាំងដឹងថានៅក្បាលខាងលើនៃសារាចរណ៍នេះ មានដាក់ថា "គណៈ៨៧០" ។

អតីតមន្ទីរសន្តិសុខចម្ការកៅស៊ូគីឡូលេខ៧ បានក្លាយទៅជាការិយាល័យផ្នែកកងជីវពលការពារចម្ការ កៅស៊ូចម្ការអណ្តូងនាពេលបច្ចុប្បន្ននេះ ។ ចំណែកឯកន្លែងកប់សាកសពដែលមានចម្ងាយពី១០០-១៥០ ម៉ែត្រពីមន្ទីរសន្តិសុខនេះ បានក្លាយទៅជាដីរាបស្មើនៃតំបន់ដំណាំកូនកៅស៊ូ ។

## ស្រុកស្រីសន្ធរ

១) វិទ្យាល័យស្រីសន្ធរ (មន្ទីរសន្តិសុខ និងទីតាំងសម្លាប់)

លេខកូតភូមិសាស្រ្ត ០៣១៤០៧

រយៈកំពស់ **(N) 11º 50'22:68"**

រយៈទទឹង **(E) 105º 05'13:86"**

មន្ទីរសន្តិសុខតំបន់មួយបានត្រូវបង្កើតឡើងនៅដើមទសវត្សរ៍ឆ្នាំ១៩៧៣ បន្ទាប់ពីទឹកដីស្រុកស្រីសន្ធរ បានក្លាយទៅជាតំបន់រំដោះ ។ ឈ្លើយសឹកជាច្រើនដែលជាកងកម្លាំងរបស់របបសាធារណរដ្ឋ

ខ្មែរ បានត្រូវចាប់ខ្លួននិងត្រូវបញ្ជូនមកឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះ ។ ជនរងគ្រោះត្រូវបានបែងចែកជាប្រភេទធ្ងន់ និង ស្រាល ហើយការរស់នៅក៏ត្រូវចែកដាច់រវាងបុរសនិងស្ត្រីដែរ ។ គេក មាស បានរស់នៅដាច់ពីប្តីរបស់គាត់ នៅក្នុងមន្ទីរសន្តិសុខតំបន់នេះ ។ គេក មាស បច្ចុប្បន្នជាអនិជនរស់នៅប្រទេសអូស្ត្រាលី (បានជួបជាមួយខ្ញុំ នៅពេលដែលគាត់បានវិលមកថែរក្សាជម្ងឺម្តាយរបស់គាត់) គឺជាអ្នកទោសដែលជាប់ចោទពីរឿងធ្លាប់បានបំពាក់ កម្រងផ្កាឲ្យសម្តេចឪ និងមានប្តីធ្វើជាតម្រួតយោធាកាលពីជំនាន់សាធារណរដ្ឋខ្មែរ ។ ពេញមួយរបបដែលគ្រប់គ្រងដោយខ្មែរក្រហម គេក មាស បានរស់នៅក្រោការឃុំឃាំងតែរយៈពេលខ្លីប៉ុណ្ណោះ គឺមុនពេល បែកថ្ងៃរំដោះឆ្នាំ១៩៧៩បន្តិច ។ មាស បានប្រាប់ថា គាត់បានជាប់គុកចំនួនបីកន្លែងគឺ មុនដំបូងគេនៅវិទ្យា ល័យស្រីសន្ធរ បន្ទាប់មកនៅវត្តទូរី និងក្រោយបង្អស់នៅស្រុកពារាំងខេត្តព្រៃវែង ។ ក្នុងរយៈពេលជាប់ឃុំឃាំង នៅវិទ្យាល័យស្រីសន្ធរ គាត់មានការលំបាកយ៉ាងខ្លាំងទាំងការហូបចុក ការធ្វើការងារ និងការរស់នៅ ។ បន្ទប់ឃុំឃាំងមួយៗរបស់អ្នកទោសគឺមានប្រដាប់ទៅដោយពាងទឹកមួយសម្រាប់ដាក់លាមករបស់អ្នកទោស ។ មាស បានត្អូញត្អែរថា គាត់មានកើតរមាសពេញខ្លួន ព្រោះសត្វសង្កើចខាំដោយសារតែគ្មានភាពអនាម័យ ។ គ្មានសម្លៀកបំពាក់សម្រាប់ផ្លាស់ប្តូរឡើយ ។ មាស បានស្គាល់អ្នកទោសដូចគាត់ចំនួនពីរនាក់ទៀតគឺ ដូឡុង រង្សី និងអ្នកដែលមានពូជពង្សវង្សត្រកូលស្តេចម្នាក់ទៀត(មិនចាំឈ្មោះ) នៅក្នុងមន្ទីរឃុំឃាំងនៅវិទ្យាល័យស្រីសន្ធរ ប៉ុន្តែក្រោយមកអ្នកទាំងពីរនោះបានត្រូវផ្លាស់ឲ្យមកភ្នំពេញ ។ ចំណែកគាត់បានត្រូវផ្លាស់ឲ្យមកនៅមន្ទីរសន្តិសុខ មួយទៀតនៅវត្តទូរី បន្ទាប់ពីមានការបែកបាក់សាមគ្គីផ្ទៃក្នុងរវាងបក្ខពួកខាងសោភឹម និងអង្គការបក្ស ។

មន្ទីរសន្តិសុខតំបន់ ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណនៃវិទ្យាល័យស្រីសន្ធរនាពេលបច្ចុប្បន្ននេះ បានបញ្ចប់អណត្តិការងាររបស់ខ្លួននៅចុងឆ្នាំ១៩៧៥ គឺជាពេលដែលបានសម្លាប់អ្នកទោសដែលជាប្រភេទធ្ងន់រួច មកនៅបរិវេណខាងក្រោយជាប់នឹងរបងវិទ្យាល័យនោះ ។ ឯអ្នកទោសស្រាល បានត្រូវដោះលែងឲ្យទៅតាម សហករណ៍ផ្សេងៗក្នុងស្រុកខ្លះ និងខ្លះទៀតបានត្រូវជម្លៀសបន្តទៅកាន់កន្លែងឃុំឃាំងផ្សេងទៀត ។ ប្តីរបស់ គេក មាស បានត្រូវសម្លាប់ដោយសារតែមានទោសធ្ងន់ពីរឿងបានជាប់និន្នាការនយោបាយពីសង្គមចាស់ ។ ទៀត អូន អាយុ៤១ឆ្នាំ រស់នៅក្នុងភូមិព្រៃកពោធិ៍ក្រោម ឃុំព្រៃកពោធិ៍ ដែលបច្ចុប្បន្នជាជាងម៉ាស៊ីន បាន និយាយថា ការសម្លាប់មនុស្សនៅក្នុងបរិវេណនៃវិទ្យាល័យស្រីសន្ធរគឺចាប់ផ្តើមសម្លាប់ខ្លាំងពីឆ្នាំ១៩៧៤ ហើយ បានបញ្ចប់ទៅវិញនៅចុងឆ្នាំ១៩៧៥ ព្រោះពេលនោះ អូន គឺជាកងចល័តស្រុកស្រីសន្ធរ ។ អូន បាន សន្និដ្ឋានថាមានចំនួនសាកសពប្រមាណ៥០០នាក់ បានស្លាប់នៅក្នុងរណ្តៅជាច្រើននៅប៉ែកខាងក្រោយជាប់នឹង របង

វិទ្យាល័យ ។ ចាប់តាំងពីដើមឆ្នាំ១៩៧៦មកដល់ថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ទីតាំងនេះត្រូវស្ថិត ក្នុងភាពទំនេរគ្មានមនុស្សរស់នៅ ប៉ុន្តែនៅតែមានឈ្មោះជាមន្ទីរសន្តិសុខតំបន់ដដែល ។

**២) វត្តព្រែកពោធិ៍មង្គល (ទីតាំងសម្លាប់)**

លេខកូតភូមិសាស្ត្រ ០៣១៨០៨

រយៈកំពស់ **(N) 11º 50'11:70"**

រយៈទទឹង **(E) 105º 05'13:86"**

ប្រជារាស្ត្រខ្មែរទូទៅតែងតែចាត់ទុកវត្តអារាម ជាកន្លែងសម្រាប់រំងាប់នូវបញ្ហាផ្សេងៗរវាងផ្លូវលោក និងផ្លូវធម៌ ហើយក៏ជាកន្លែងដែលអប់រំមួយផ្នែកឲ្យមនុស្សចេះស្វែងយល់ពីបុណ្យនិងបាប ។ ប៉ុន្តែផ្ទុយទៅវិញ វត្តអារាមគឺជាកន្លែងមួយដែលផ្តល់ភាពងាយស្រួលក្នុងការសម្លាប់មនុស្សនារបបខ្មែរក្រហមទៅវិញ ។ បរិវេណ នៃវត្តព្រែកពោធិ៍ បានក្លាយទៅជាទីតាំងសម្លាប់មនុស្សកាលពីចន្លោះឆ្នាំ១៩៧៦និង១៩៧៨ ។

បន្ទាប់ពីមន្ទីរសន្តិសុខនៅវិទ្យាល័យស្រីសន្ធរត្រូវរំលាយទៅ ការសម្លាប់មនុស្សនៅក្នុងវត្តព្រែកពោធិ៍ មង្គលបានចាប់ផ្តើមឡើង ។ ព្រះវិហារ និងសាលាឆាន់ បានត្រូវយកធ្វើជាកន្លែងឃុំឃាំងបណ្តោះអាសន្ននៃ អ្នកទោសទាំងឡាយដែលបានដឹកជញ្ជូនមកពីគ្រប់កន្លែង ។ ការសម្លាប់បានប្រព្រឹត្តិទៅនៅពេលយប់ចាប់ពីម៉ោង ៧រហូតដល់ម៉ោង៨ទៀបភ្លឺ និងជួនកាលបន្តរហូតដល់ម៉ោង៧ព្រឹក ។ ការសម្លាប់មនុស្សបានចាប់ផ្តើមឡើង នៅឆ្នាំ១៩៧៦ ប៉ុន្តែមិនទាន់មានសម្លាប់ច្រើនទេ ។ លុះមកដល់ឆ្នាំ១៩៧៨ ការសម្លាប់បានធ្វើឡើងទ្រង់ទ្រាយ ទៅលើជនរងគ្រោះទាំងឡាយនោះ ។ រណ្តៅធំៗដែលបានជីករួចជាស្រេច គឺជារណ្តៅដែលត្រៀមកប់សាក សពដែលបានសម្លាប់ ។ រណ្តៅទាំងនោះបានជីកឡើងនៅតាមចន្លោះដើមដូងដែលស្ថិតនៅប៉ែកខាងជើង និង ខាងត្បូងព្រះវិហារព្រែកពោធិ៍មង្គល ។ ទៀត អួន បានអះអាងថាខ្លួនគឺជាអ្នកដែលបានសែងខ្មោចយកទៅកប់ ចោលនៅក្នុងរណ្តៅដែលបានជីករួចនោះ ។ អួន បានប្រាប់ថា មានចំនួនពី៣០ទៅ៤០រណ្តៅដែលមានផ្ទុក សាកសព ហើយដែលក្នុងមួយរណ្តៅៗមានសាកសពពី១០ទៅ១៥នាក់ ។ ភាគច្រើននៃជនរងគ្រោះដែលបានស្លាប់នោះ គឺជាប្រជាជន១៧មេសា អ្នកជាប់និន្នាការពីសង្គមចាស់ ជាប់ខ្សែយួន ខ្សែចាម និងខ្សែចិន ។ ឧបករណ៍សំខាន់ក្នុងការសម្លាប់គឺមានដំបង និងដែកគោលរទេះ ។ អួន បានរាយការណ៍ពីមូលហេតុនៃការសម្លាប់ នេះថា មកពីអ្នកទោសទាំងនោះបានបំផ្លាញអង្គការលើគ្រប់វិស័យ ។ ការសម្លាប់មនុស្សនៅវត្តព្រែកពោធិ៍មង្គល គឺប្រព្រឹត្តិទៅក្នុងលក្ខណៈអាថ៌កំបាំងបំផុត ។ ម៉ាស៊ីនភ្លើងបានត្រូវបញ្ឆេះឡើងយ៉ាងលាន់ឮពេញទីធ្លាវត្ត ដើម្បីកុំឲ្យមានការស្តាប់ឮនូវការសម្លាប់មនុស្សនេះពីប្រជាជនដែលរស់នៅ

ជាប់នឹងបរិវេណវត្ត ។ គំនរខោអាវ យ៉ាងច្រើនសន្ធឹកសន្ធាប់បានស្ថិតនៅលើខឿននៃព្រះវិហារ និងនៅលើសាលាឆាន់ ។ អូន និយាយថា មុនពេល សម្លាប់ខ្មែរក្រហមបានបញ្ជាឲ្យដោះខោអាវចេញអស់ពីជនរងគ្រោះ ហើយក្រវែងគរចោលនៅលើឥដ្ឋយ៉ាង រាយប៉ាយ ។ រហូតមកដល់ថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ គំនរខោអាវទាំងនោះនៅតែគ្មាននរណារុះរើ ឡើយ ប៉ុន្តែចាប់ពីឆ្នាំ១៩៨០មក គំនរខោអាវនេះត្រូវជជុះរើយ៉ាងពាសវាលពាសកាល ។ ចំណែកឯរណ្តៅទាំងឡាយបានត្រូវគាស់ក្នុងបំណងស្វែងរកមាសពីសំណាក់ប្រជាពលរដ្ឋក្នុងភូមិ ។ ចំណែកវត្ថុតាងនានាដូចជា ដំបង ដែកក្រៀវទេះក៏ត្រូវស្ថិតនៅនឹងកន្លែងកើតហេតុដែរ ។

៣) ឡពាង (ទីតាំងសម្លាប់)

លេខកូតភូមិសាស្ត្រ ០៣១៨០៩

រយៈកំពស់ **(N) 11º 50'22:68"**

រយៈទទឹង **(E) 105º 07'09:30"**

ឡពាង គឺជាឈ្មោះដែលអ្នកស្រុកនៅភូមិទូរីក្រោម ឃុំព្រែកពោធិ៍ និយមហៅគ្រប់ៗរូបតាំងពីដើម រៀងមករហូតដល់បច្ចុប្បន្ននេះ ។ រឿងរ៉ាវនៃទីតាំងឡពាងនេះបានត្រូវរៀបរាប់ប្រាប់ថាជាកន្លែងផលិតពាង គ្រប់ប្រភេទកាលពីជំនាន់សង្គមចាស់ ។ លុះមកដល់ជំនាន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ឡពាងបានក្លាយទៅ ជាកន្លែងសម្លាប់មនុស្សយ៉ាងសាហាវមួយនៅឃុំព្រែកពោធិ៍ ។ រហូតមកដល់បច្ចុប្បន្ននេះ ប្រជាពលរដ្ឋដែល រស់នៅក្នុងស្រុកស្រីសន្ធរទាំងមូលសុទ្ធតែបានដឹងគ្រប់គ្នាថា អតីតឡពាងកាលពីសង្គមចាស់ គឺជាកន្លែងសម្លាប់ មនុស្សរបស់ខ្មែរក្រហម ។ ប៉ៅ ឆួន អាយុ៥៣ឆ្នាំ រស់នៅភូមិទីរីក្រោម ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ បានប្រាប់ឲ្យដឹងថា ការសម្លាប់មនុស្សនៅឡពាងនេះ គឺប្រព្រឹត្តទៅនៅឆ្នាំ១៩៧៨ ដោយខ្មែរក្រហមខាងភូមិភាគនិរតី ។ ជនរងគ្រោះ គឺជាប្រជាជនដែលរស់នៅក្នុងឃុំព្រែកពោធិ៍ទាំងមូល និងមួយចំនួនទៀតបានត្រូវដឹកឡានធំៗមកកាន់ទីតាំងនេះទាំងពេលថ្ងៃ ។ គ្មាននរណាម្នាក់បានឃើញការសម្លាប់មនុស្សនៅទីតាំងឡពាងដោយ ផ្ទាល់នឹងភ្នែកឡើយ ។ ឆួន បានប្រាប់បន្តថា ការដឹកជញ្ជូនមនុស្សចូលមកកាន់ទីតាំងសម្លាប់ឡពាង ហាក់ដូចជា ក្បួនហែរកឋិនមួយអញ្ចឹង ។ ប្រជាជនដែលរស់នៅជាប់នឹងបរិវេណទីតាំងសម្លាប់នោះ មិនហ៊ានទៅក្បែរៗឡើយ ព្រោះខ្លាចស្លាប់ដោយសារតែចង់ដឹងហេតុការណ៍ ។ ពក វ៉ាន់ឌិន អាយុ៥៨ឆ្នាំ ជាប្រជាជនរស់នៅក្នុង ភូមិព្រែកពោធិ៍ក្រោម ឃុំព្រែកពោធិ៍ បានរៀបរាប់ប្រាប់ពីហេតុការណ៍ដែលគាត់បានពើបប្រទះឃើញផ្ទាល់ថា ច្រើនបានរសាត់មកជាប់នឹងមងរបស់គាត់ពេលប្រាំងទន្លេកន្លែងឡពាងនោះបានបាក់ចូលក្នុងទឹក

ទន្លេថា ថ្ងៃមួយ (មិនចាំ) ពេលដែលគាត់បានទៅវាយមងនៅពីមុខប្រាំងទន្លេដែលជាអតីតកន្លែងកប់ខ្មោចកាលពីជំនាន់ខ្មែរ ក្រហមនៅឡពាង ស្រាប់តែយប់ឡើងប្រាំងទន្លេនោះបានបាក់ស្រុតចូលទៅក្នុងទឹកទន្លេអស់ជាច្រើនម៉ែត្រ ។ រណ្តៅកប់ខ្មោចជាច្រើនបានត្រូវបាក់ទៅជាមួយដីនោះទៅក្នុងទន្លេ ។ លុះព្រឹកឡើង វ៉ាន់ឌិន បានទៅដោះត្រី ស្រាប់តែប្រទះឃើញមងរបស់គាត់មានជាប់សុទ្ធតែលលាដ៏ក្បាល និងឆ្អឹងជាច្រើនទៀត ។ វ៉ានឌិន បន្តថា មិនត្រឹមតែគាត់ប៉ុណ្ណោះទេ សូម្បីតែអ្នកឯទៀតក៏ដូច្នេះដែរ ។ ស្ថិតក្នុងសភាពបែបនេះ ម្ចាស់មងខ្លះបានត្រូវបោះ បង់ចោលមងរបស់ខ្លួនទៅជាមួយលលាដ៏ក្បាល និងឆ្អឹងនោះនៅក្នុងទឹកទន្លេរហូតទៅ ។ ចំណែក វ៉ាន់ឌិន មិនដូច្នោះទេ គាត់បានចុះដោះលលាដ៏ក្បាល និងឆ្អឹងទាំងនោះចេញពីមងរបស់គាត់បោះចោលទៅក្នុងទឹកទន្លេអស់ទៅ ហើយសារមងត្រឡប់មកផ្ទះវិញដែលមានជាប់ត្រីយ៉ាងច្រើនផង ។ វ៉ាន់ឌិន និងមិត្តភក្តិគាត់ពីរបីនាក់ទៀត មានឈ្មោះ អូន និងគីមហេង រស់នៅក្នុងភូមិ-ឃុំជាមួយគ្នា បានរំឭករឿងរ៉ាវនៃការសម្លាប់មនុស្សនៅឡពាងប្រាប់ខ្ញុំថា មានសម្លាប់ភាគច្រើនជាកម្មាភិបាលខ្មែរក្រហមខាងបូព៌ា ព្រោះការសម្លាប់នេះបានប្រព្រឹត្តិទៅនៅអំឡុងឆ្នាំ១៩៧៧-៧៨ដែលជាការកាន់កាប់យ៉ាងពេញទំហឹងរបស់ខ្មែរក្រហមខាងនិរតី ។ ហ៊ុយ លី និង ហ៊ុយ សេង គឺជាកម្មាភិបាលធំៗប្រចាំស្រុកស្រីសន្ធរ និងកូនចៅក្រោមបង្គាប់ជាច្រើនទៀតបានត្រូវដឹកតាមរទេះសេះយកមកសម្លាប់ចោលនៅទីតាំងឡពាងនេះទាំងអស់ ។ ការសម្លាប់មិនបានប្រើអាវុធជាឧបករណ៍ទេ ។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ វត្ថុតាងដែលនៅសល់រួមមានរណ្តៅជាច្រើន និងដែកក្រៀវទេះដែលមានរុំក្រណាត់ ដើម្បីទ្រាប់ដៃក្នុងការវាយប្រហារមនុស្ស ។ ដែកក្រៀវទេះនេះបានត្រូវប្រមូលទុកដាក់យ៉ាងត្រឹមត្រូវនៅក្បែរ កន្លែងកើតហេតុ ។ ប៉ុន្តែបន្ទាប់ពីប្រាំងទន្លេត្រូវបាក់ទៅភស្តុតាងទាំងនោះបានត្រូវបាត់ស្រមោលអស់ដែរ ។ ឆ្អឹងមួយភាគធំត្រូវបាត់អស់ដោយសារតែការបាក់ប្រាំងទន្លេនេះ ។ ចំណែកមួយភាគតូចដែលបានមកពីការដើរ រើសនៅលើដីបន្ទាប់ពីមានការបាក់ប្រាំងរួច បានត្រូវប្រជាពលរដ្ឋដែលបច្ចុប្បន្នមានទីលំនៅនៅក្បែរៗនោះ យកមកតម្កល់ក្នុងក្ដារមឈូសធ្វើពីបន្ទះក្ដារមួយហើយបានយកទៅកប់ក្នុងដីក្រោមដើមឈើមួយ ។ ការកប់នេះ បានធ្វើឡើងបន្ទាប់ពីមានការឯកភាពគ្នារវាងប្រជាជនក្នុងភូមិទាំងអស់ ។ នៅពេលដែលខ្ញុំបានទៅស្រាវជ្រាវ ដល់ទីកន្លែងមានប្រជាពលរដ្ឋជាច្រើននាក់បានប្រាប់ថា អដ្ឋិធាតុនេះបានកប់តែក្នុងរយៈពេលថ្មីៗនេះបន្តិច ។ មានរណ្តៅជាច្រើនទៀត មិនទាន់បានបាក់ស្រុតនៅឡើយទេ ។ ចម្ការចេកជាច្រើនគុម្ពបានដាំពីលើរណ្តៅទាំងនោះ ។ ភាពបាក់ស្រុតដោយសារតែចរន្តទឹកហូរ នឹងអាចធ្វើឲ្យមានការបាក់ស្រុតបន្ថែមទៀតនាឆ្នាំខាងមុខ ។ ប្រជារាស្ត្រម្នាក់(មិនស្គាល់ឈ្មោះ)បាននិយាយថាប្រាំងទន្លេនេះ មានបាក់ជារៀងរាល់ឆ្នាំមិនដែលខានឡើយ ។

ទោះជាប៉ុន្មានឆ្នាំខាងមុខទៀតនេះ ចរន្តខ្សែទឹកបានបុកទំលាយច្រាំងទន្លេនៃទីតាំងសម្លាប់ឡាពាង អស់គ្មាន សល់ក៏ដោយ ប៉ុន្តែអ្វីដែលស្ថិតនៅក្នុងផ្នត់គំនិតរបស់ប្រជាពលរដ្ឋទូទៅថាជាទីតាំងសម្លាប់មនុស្សនោះ គឺពិតជា មិនអាចបំភ្លេចបានឡើយ ។

មានសាកសពរាប់ពាន់នាក់ បានត្រូវសម្លាប់ដោយដំបង និងដែកក្បៀរទេះ ។ សាកសពទាំងអស់បានកប់នៅក្នុងរណ្ដៅជាច្រើន(មិនអាចរាប់បាន) ជាប់នឹងច្រាំងទន្លេដែលជាអតីតឡដុតពាងគ្រប់ប្រភេទ ។

ស្រុកកងមាស

**ទីតាំងដែលមិនបានទៅដល់**

១) វត្តគុហារ

ស្ថិតនៅភូមិសំរោង ឃុំព្រៃកុយ

ទីតាំងនេះមានសម្លាប់នៅប៉ែកខាងក្រោយវត្តប្រហែល២០ - ៣០ម៉ែត្រ ។

ជនរងគ្រោះគឺបាន ប្រមូលមកពីគ្រប់ភូមិទាំងអស់ក្នុងឃុំ ។

២) វត្តអង្គរបាន

ស្ថិតនៅក្នុងភូមិ...................ឃុំ.......................

ទីតាំងនេះគ្រាន់តែជាកន្លែងស្តុបប្រជាជនមួយរយៈប៉ុណ្ណោះមុននឹងយកទៅសម្លាប់ចោលនៅប៉ែកខាងក្រោយវត្តប្រហែល២០ម៉ែត្រ ។ ការសម្លាប់ប្រព្រឹត្តិទៅចាប់ពីម៉ោង ៧ល្ងាចរហូត ដល់ម៉ោង៨ភ្លឺ និងជួនកាលបន្តរហូតដល់ម៉ោង៧ព្រឹក ។

៣) ស្វាយពន្ធ័

ស្ថិតនៅក្នុងភូមិ........................ ឃុំខ្ចៅ

ប្រភេទជនរងគ្រោះជាប្រភេទប្រជាជន១៧មេសា និងអ្នកជាប់និន្នាការពីសង្គម ។

៤) ទួលកុកឃូ

ស្ថិតនៅឃុំសំរោង (ទល់មុខព្រៃចារ)

ទីតាំងនេះមានអ្នកស្លាប់ប្រមាណ ២០០០នាក់ ។